CAM-PAINT

ថ្នាំពណ៌ជាតិ

# ពត៌មាន សង្ខេប
# ក្រុមហ៊ុន និង ផលិតផល

## ខេមបុឌាន ខេមីខល សឹបផ្លាយ

# មាតិកា

ប្រវត្តិសង្ខេបរបស់ក្រុមហ៊ុន.......... ១

រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន.......... ៣

ផលិតផលរបស់ក្រុមហ៊ុន.......... ៤

ថ្នាំលាបប្រភេទលាយទឹក.......... ៤

ថ្នាំលាបប្រភេទលាយប្រេង.......... ៨

ផលិតផលបាយអស្ទូត .......... ១១

ផលិតផលគីមីសំណង់.......... ១៤

ដៃគូរអាជីវកម្មរបស់ក្រុមហ៊ុន.......... ១៦

អតិថិជននិងសមិទ្ធិផលរបស់ក្រុមហ៊ុន.......... ១៧

ទំនួលខុសត្រូវក្នុងសង្គមរបស់ក្រុមហ៊ុន.......... ២១

អាសយដ្ឋាន និងទំនាក់ទំនងក្រុមហ៊ុន.......... ២៣

បណ្ដាញចែកចាយរបស់ក្រុមហ៊ុន.......... ២៤

# ប្រវត្តិសង្ខេបក្រុមហ៊ុន

ក្រុមហ៊ុន **ខេមបូឌាន ខេមីខល ស៊ីបផ្លាយ (ខាំ-ផែន)** ជាក្រុមហ៊ុនផលិតថ្នាំពណ៌ខ្មែរ ដែលបានចាប់ផ្តើមអាជីវកម្មរបស់ខ្លួននៅក្នុងឆ្នាំ ២០០៤ ទន្ទឹមនឹងការវិវឌ្ឍន៍យ៉ាងឆាប់រហ័សលើវិស័យស្ថាបត្យកម្មសំណង់នៅទូទាំងប្រទេស ដើម្បីចូលរួមចំណែក ក្នុងការបង្កើនការផលិតផលិតផលក្នុងស្រុក ។ មកដល់ត្រឹមឆ្នាំ២០១៤ ដែលមានរយៈពេលត្រឹមតែ១០ឆ្នាំប៉ុណ្ណោះ ក្រោមកិច្ចដឹកនាំប្រកបដោយទេពកោសល្យ និងទស្សនវិស័យដ៏ច្បាស់លាស់ ពីថ្នាក់ដឹកនាំ ជាមួយនឹងឆន្ទៈតស៊ូ ព្យាយាមដ៏មោះមុត ពីសំណាក់ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ បានប្រែក្លាយក្រុមហ៊ុន ដ៏តូចមួយឱ្យឈានមកជាក្រុមហ៊ុនមួយដែលមានឈ្មោះបោះសំលេងលើទីផ្សារ មានការទទួលស្គាល់ និងជឿជាក់ពីសំណាក់ប្រជាពលរដ្ឋនៅទូទាំងប្រទេស លើគុណភាពផលិតផល សេវាកម្ម និង កេរ្តិ៍ឈ្មោះលើភាពជាអ្នកដឹកនាំរបស់ស្ថាបនិកក្រុមហ៊ុន ។ លើសពីនេះទៅទៀត **ខាំ-ផែន** ក៏ជាក្រុមហ៊ុនក្នុងស្រុកមួយដែលមានផលិតផល អាចប្រកួតប្រជែងជាមួយក្រុមហ៊ុនលំដាប់ថ្នាក់អន្តរជាតិ ដែលមានអាយុរាប់រយឆ្នាំបាន ។ ក្រុមហ៊ុននេះត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយជនជាតិខ្មែរបីរូបគឺ(១)លោក សំ ពូក (២)លោក សោម សម្បត្តិ និង(៣)លោក អ៊ីវ គីមស្វា។ នៅចុងឆ្នាំ ២០១៦ ក្រុមហ៊ុនបានរៀបចំអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាព ISO 9001:2015 ក្រោមកិច្ចសហការពីអង្គការផលិតភាពអាស៊ី (APO) និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

## *ទស្សនវិស័យ*

នឹងក្លាយជាក្រុមហ៊ុនផលិតថ្នាំលាបក្នុងស្រុកមួយដែលគួរឱ្យជឿទុកចិត្ត ដោយយើងបានផលិតនូវផលិតផលដែលធានាលើគុណភាព និង មានសោភ័ណ្ឌ។

## *បេសកកម្ម*

ផលិតនូវផលិតផលដែលឆ្លើយតបទៅនឹងតម្រូវការ និងការចង់បានរបស់អតិថិជនគ្រប់ចំណែកទីផ្សារ ដោយធ្វើឱ្យប្រាកដថាផលិតផលទាំងនោះអាចប្រកួតប្រជែងបានទាំងលើបរិមាណ និងគុណភាព។

## *ទស្សនវិជ្ជា*

យើងត្រូវតែផ្តល់ឱ្យអតិថិជននូវផលិតផលដែលមានគុណភាព និងមានការប្រកួតប្រជែងលើថ្លៃ ស្របពេលជាមួយគ្នានេះដែរ យើងក៏មិនភ្លេច ការផ្តល់នូវសេវាកម្មល្អ និងបង្កើតទំនាក់ទំនងល្អជាមួយអតិថិជនរបស់យើងដែរ ដោយយើងយល់ថា ប្រាក់ចំណេញ និងការរីកលូតលាស់របស់ក្រុមហ៊ុនគឺអតិថិជន ជាអ្នកផ្តល់អោយ ។

## *គោលនយោបាយ*

យើងអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិក ស្របពេលជាមួយការអភិវឌ្ឍន៍ ក្រុមហ៊ុន។ ដោយយល់ថាគ្រប់គ្នាមិនថា នាយក អ្នកគ្រប់គ្រងកម្រិតលើ អ្នកគ្រប់គ្រងថ្នាក់កណ្តាល បុគ្គលិកធម្មតា និងកម្មករទាំងអស់គ្នាជាអ្នកធ្វើអោយអាជីវកម្មមានដំណើរការ និងជាអ្នកចាត់ចែងការងារក្នុងក្រុមហ៊ុនទាំងមូល ដូច្នេះយើងត្រូវតែផ្តល់តម្លៃ និងបណ្តុះបណ្តាលធនធានមនុស្សរបស់យើងអោយបានល្អជាទីបំផុត។

## តម្លៃស្នូល

- គុណភាព: យើងផ្តល់អោយអតិថិជនរបស់យើងទាំងគុណភាពផលិតផល និងគុណភាពសេវាកម្ម។
- មិត្តភាព: យើងធ្វើការបំរើអតិថិជនរបស់យើងដោយស្រស់ស្រាយ និងរួសរាយរាក់ទាក់។
- សុចរិតភាព: មិនបន្លំ មិនបំភ្លៃ មិនបំផ្លើស ។

## គណៈកម្មការនាយក



## STRUCTURE MANAGEMENT- ORG.CHART



## ផលិតផលរបស់ក្រុមហ៊ុន

គ្រប់ផលិតផលរបស់ក្រុមហ៊ុន ខេមបូឌាន ខេមីខល សឹបផ្លាយ ត្រូវបានផលិតឡើងក្រោមបច្ចេកវិទ្យា និងស្តង់ដារធំៗ ពីប្រទេសអាឡឺម៉ង់ អាមេរិក សិង្ហបុរី និងជប៉ុន។ ភាគច្រើននៃវត្ថុធាតុដើមរបស់យើងគឺត្រូវបាននាំចូលពីប្រទេស អាឡឺម៉ង់ និងអាមេរិក។ រាល់ការអភិវឌ្ឍន៍ផលិតផលថ្មីនិមួយៗ ត្រូវស្ថិតក្រោមការស្រាវជ្រាវ និងការពិសោធន៍យ៉ាងច្បាស់លាស់របស់ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍ ចាប់ពីរយៈពេល ០៦-១២ ខែ។

ខាងក្រោមជាផលិតផលដែលក្រុមហ៊ុនមានមកដល់ពេលបច្ចុប្បន្ន៖

## ថ្នាំលាបប្រភេទលាយទឹក




**សារិកា (SARIKA)**

**Wonder Hiding**

- ប្រភេទផលិតផល: *ភ្លឺខ្លាំង និង រលោងល្អ* ។
- លក្ខណពិសេសនៃផលិតផល: សារិកា (SARIKA) ជាថ្នាំលាបចំណោញ ដែលធានាគុណភាព គ្រប់រដូវកាល សាច់រឹងស្អិត ហើយភ្លឺរលោង ការពារ ផ្សិត ស្លែ មិនស្រូវកាន់ធូលី អាចលាងសំអាតស្នាមប្រឡាក់បានយ៉ាងងាយស្រួល។
- ចំណាត់ថ្នាក់ផលិតផល: ថ្នាំលាបលំអប្រភេទលាយទឹក មានគុណភាពកម្រិតខ្ពស់ ធានាជាប់លើស **88 ខែ** ។
- ការប្រើប្រាស់: លាបបានទាំងក្នុង និងក្រៅ លាបដើម្បីលំអ និងការពារ។
- ចំណុះ: 18 លីត្រ 3.8 លីត្រ និង 1លីត្រ
- ទំហំគ្របដណ្តប់: 155-166m² / ធុង 18 លីត្រ (សម្រាប់ការរុញ/លាប ២ទឹក)
- ពណ៌: អាចជ្រើសរើសបានគ្រប់ពណ៌តាមតម្រូវការ
- គោលដៅប្រើប្រាស់: សំណង់ប្រណិតគ្រប់ប្រភេទ




# វីតាល់ (VITAL)

## Ultra Fine

- **ប្រភេទផលិតផល:** ភ្លឺល្មម
- **លក្ខណពិសេសនៃផលិតផល:** វីតាល់ (VITAL) ជាថ្នាំលាប ចំណេញ ដែលធានាគុណភាព គ្រប់រដូវកាល សាច់ស្អិត ហើយភ្លឺរលោងល្មមការពារ ផ្សិត ស្លែ មិនស្រូវកាន់ធូលី អាចលាងសំអាតស្នាមប្រឡាក់បានយ៉ាងងាយស្រួល។
- **ចំណាត់ថ្នាក់ផលិតផល:** ថ្នាំលាបលំអប្រភេទលាយទឹក មានគុណភាពកម្រិតខ្ពស់ដែលធានាជាប់លើស **88 ខែ**។
- **ការប្រើប្រាស់:** លាបបានទាំងក្នុង និងក្រៅ លាបដើម្បីលំអ និងការពារ។
- **ចំណុះ** ៖ 15 លីត្រ 3.8 លីត្រ និង 1 លីត្រ
- **ទំហំគ្របដណ្តប់:** **111-122 m²**/ ធុង 15 លីត្រ (សម្រាប់ការរុញ/លាប ២ទឹក)
- **ពណ៌:** អាចជ្រើសរើសបានគ្រប់ពណ៌តាមតម្រូវការ
- **គោលដៅប្រើប្រាស់:** សំណង់ប្រណិតគ្រប់ប្រភេទ



# ផែនតិក្ស ស៊ុបពើ

## PAINTEX SUPER

- **ប្រភេទផលិតផល:** សាច់រលោង មិនចាំងភ្លឺ
- **លក្ខណពិសេសនៃផលិតផល:** **Paintex Supper "Matte Finish"** ជាប្រភេទថ្នាំលាបដែលធានាគុណភាពគ្រប់រដូវកាល មិនស្រូវកាន់ធូលី និង អាចលាងសំអាតស្នាមប្រឡាក់បាន។
- **ចំណាត់ថ្នាក់ផលិតផល:** ថ្នាំលាបលំអប្រភេទលាយទឹក ធានាជាប់លើស **66ខែ**
- **ការប្រើប្រាស់:** លាបបានទាំងក្នុង និង ក្រៅ លាបដើម្បីលំអ និងការពារ។
- **ចំណុះ** ៖ 18 លីត្រ 3.8 លីត្រ និង 1 លីត្រ
- **ទំហំគ្របដណ្តប់:** **88-99 m²** / ធុង 18 លីត្រ (សម្រាប់ការរុញ/លាប ២ទឹក)
- **ពណ៌:** អាចជ្រើសរើសបានគ្រប់ពណ៌តាមតម្រូវការ
- **គោលដៅប្រើប្រាស់:** សំណង់ គ្រប់ប្រភេទ




# ហូមី (HOMY)

## Flat Paint

- <u>ប្រភេទផលិតផល:</u> ធម្មតា
- <u>លក្ខណពិសេសនៃផលិតផល:</u> ហូមី ជាប្រភេទផលិតផល ដែលផលិតឡើង ផ្សំជាមួយជាតិអាគ្រីលិក ដែលនាំចូលពីបរទេស មានគុណភាពអាចទទួលយកបានពេលការប្រើប្រាស់ តម្លៃមានការប្រកួតប្រជែង។
- <u>ចំណាត់ថ្នាក់ផលិតផល:</u> ថ្នាំលាបលំអប្រភេទលាយទឹក មានគុណភាពកម្រិតល្មមធ្យម
- <u>ការប្រើប្រាស់:</u> លាបបានទាំងក្នុង និង ក្រៅ
- <u>ខ្នាត</u> ៖ 26 Kg និង 5 Kg
- <u>ទំហំគ្របដណ្តប់:</u>
  ហូមីក្នុង **44-45 m²** ហូមីក្រៅ **55-66 m²** / ធុង 26 kg (សម្រាប់ការរុញ/លាប ២ទឹក)
- <u>ពណ៌:</u> អាចជ្រើសរើសបានគ្រប់ពណ៌តាមតម្រូវការ
- <u>គោលដៅប្រើប្រាស់:</u> សំណង់ ពាណិជ្ជកម្ម និង ឧស្សាហកម្មទូទៅ




# ម៉ែក្ស អេក្សត្រា អ៊ី

## (MAX EXTRA-E)

- <u>ប្រភេទផលិតផល:</u> ថ្នាំទ្រនាប់
- <u>លក្ខណពិសេសនៃផលិតផល:</u> **MAX EXTRA-E** ជាប្រភេទថ្នាំទ្រនាប់ការពារក្រឡា-ខ្លឹង និងជួយកាត់បន្ថយកំដៅ ។
- <u>ចំណាត់ថ្នាក់ផលិតផល:</u> ថ្នាំទ្រនាប់ប្រភេទលាយទឹក មានគុណភាពល្អបំផុត និងប្រើចំណេញជាងគេ។
- <u>ការប្រើប្រាស់:</u> លាបបានទាំងក្នុង និង ក្រៅ លាបលើផ្ទៃ ស៊ីម៉ងត៍ ដើម្បីការពារ និងរក្សា ថ្នាំពណ៌ស្រទាប់ខាងលើអោយជាប់ និងមានសោភណភាពបានយូរ។
- <u>ចំណុះ</u> ៖ 18 លីត្រ 3.8 លីត្រ
- <u>ទំហំគ្របដណ្តប់:</u> **155-166 m²** / ធុង 18លីត្រ (សម្រាប់ការរុញ/លាប ១ទឹក)
- <u>គោលដៅប្រើប្រាស់:</u> សំណង់ប្រណិតគ្រប់ប្រភេទ




# ព្រេវ៉ាឡិន
# (PREVALENT)

- **ប្រភេទផលិតផល:** ថ្នាំទ្រនាប់សំរាប់ជញ្ជាំងថ្មី
- **លក្ខណពិសេសនៃផលិតផល:** PREVALENT ជាប្រភេទថ្នាំទ្រនាប់ ដែលមានកំរោប់ល្អ ជាប់ស្អិត និងលាបបានច្រើនការ៉េ ។
- **ចំណាត់ថ្នាក់ផលិតផល:** ថ្នាំទ្រនាប់ប្រភេទលាយទឹក គុណភាពកម្រិតល្អបង្គួរ។
- **ការប្រើប្រាស់:** លាបបានទាំងក្នុង និង ក្រៅ លាបលើផ្ទៃ ស៊ីម៉ងត៍ថ្មី ដើម្បីការពារ និងក្រោថ្នាំពណ៌ស្រទាប់ខាងលើអោយជាប់ និងមានសោភណភាពបានយូរ។
- **ទម្ងន់:** 26 Kg និង 5Kg
- **ទំហំគ្របដណ្តប់:** 144-155 m² / ធុង 26 Kg (សម្រាប់ការបាញ់/លាប ១ទឹក)
- **គោលដៅប្រើប្រាស់:** សំណង់ គ្រប់ប្រភេទ




# ប្រូតាន់
# (PROTAN)

- **ប្រភេទផលិតផល:** ថ្នាំទ្រនាប់សម្រាប់ជញ្ជាំងចាស់
- **លក្ខណពិសេសនៃផលិតផល:** PROTAN ជាប្រភេទថ្នាំទ្រនាប់សម្រាប់ជញ្ជាំងចាស់ផលិតឡើងដោយអាគ្រីលីក មានម៉ូលេគុលល្អិត ជាប់ស្អិត ដែលមានលក្ខណពិសេសក្នុងការកែលំអ ផ្ទៃដែលផុយ រឺ ហុយ ទៅជារឹងមាំ និងរលោង ។
- **ចំណាត់ថ្នាក់ផលិតផល:** ថ្នាំទ្រនាប់ប្រភេទលាយទឹក មានគុណភាពល្អ និងប្រើចំណេញជាងគេ។
- **ការប្រើប្រាស់:** លាបបានទាំងក្នុងនិងក្រៅ លាបលើផ្ទៃស៊ីម៉ងត៍ចាស់ដើម្បីជួយអោយផ្ទៃជញ្ជាំងមានភាពរឹងមាំ និង ការពារថ្នាំពណ៌ស្រទាប់ខាងលើ អោយជាប់ និងមានសោភណភាពបានយូរ។
- **ចំណុះ:** 18 លីត្រ និង 3.8 លីត្រ
- **ទំហំគ្របដណ្តប់:** 177-188 m² / ធុង 18លីត្រ (សម្រាប់ការបាញ់/លាប ១ទឹក)
- **គោលដៅប្រើប្រាស់:** សំណង់ គ្រប់ប្រភេទ



# អេថប
# (ATOP)

- <u>ប្រភេទផលិតផល:</u> ថ្នាំលាបក្បឿង និងក្រំ
- <u>ចំណាត់ថ្នាក់ផលិតផល:</u> ថ្នាំលាបល័អប្រភេទលាយទឹក មានគុណភាពល្អ និងប្រើ ចំណេញជាងគេ។
- <u>ការប្រើប្រាស់:</u> លាបលើផ្ទៃក្បឿង និង ក្រំ ដើម្បីសោភណភាពបានយូរ។
- <u>ចំណុះ:</u> 18លីត្រ 3.8 លីត្រ និង 1 លីត្រ
- <u>ទំហំគ្របដណ្តប់:</u> 111-122 $m^2$/ ធុង 18 លីត្រ (សម្រាប់ការរុញ/លាប ២ទឹក)
- <u>ពណ៌:</u> មានច្រើនជម្រើស
- <u>គោលដៅប្រើប្រាស់:</u> លាបលើក្បឿង និងក្រំគ្រប់ប្រភេទ



# ចាបមាស
# (JAB MEAS)

- <u>ប្រភេទផលិតផល:</u> ថ្នាំទឹកមាសលាយទឹក
- <u>លក្ខណពិសេសនៃផលិតផល:</u> ចាបមាស ជាប្រភេទផលិតផល ដែលធានាគុណភាព លេចពណ៌ទឹកមាសច្បាស់ ភ្លឺ កាន់ពណ៌បានយូរ។
- <u>ចំណាត់ថ្នាក់ផលិតផល:</u> ថ្នាំលាបល័អប្រភេទលាយទឹក មានគុណភាពខ្ពស់បំផុត។
- <u>ការប្រើប្រាស់:</u> លាបលើផ្ទៃស៊ីម៉ងត៍ ឈើ និង ដែក (ដែលមានលាបថ្នាំទ្រនាប់) ។
- <u>ចំណុះ</u> ៖ 18លីត្រ 3.8 លីត្រ និង 1 លីត្រ
- <u>ទំហំគ្របដណ្តប់:</u> 122-133 $m^2$ / ធុង 18 លីត្រ (សម្រាប់ការរុញ/លាប ២ទឹក)
- <u>គោលដៅប្រើប្រាស់:</u> សំណង់ប្រណិត និង វិចិត្រសិល្បៈគ្រប់ប្រភេទ

# ថ្នាំលាបប្រភេទលាយប្រេង



## សេកថ្មី PARROT
## ភ្លឺស្មោះ គុណល្អឥតខ្ចោះ
## សព្វសាធុការ

- <u>ប្រភេទផលិតផល:</u> ថ្នាំប្រេង ភ្លឺរលោងខ្លាំង
- <u>លក្ខណពិសេសនៃផលិតផល:</u> PARROT ជាថ្នាំលាបប្រភេទលាយប្រេង ដែលងាយស្រួលលាបជាងគេ មានលំហូរល្អ លាបជិតល្អ ចំណេញ ភ្លឺខ្លាំង និង សាច់ស្អាត។
- <u>ចំណាត់ថ្នាក់ផលិតផល:</u> ថ្នាំលាបប្រភេទលាយប្រេង ដែលមានគុណភាពខ្ពស់ ។
- <u>ការប្រើប្រាស់:</u> ប្រើបានទាំងក្នុង និង ក្រៅ លាបលើដែក និង ឈើដើម្បីលំអ និង ការពារ ។
- ចំណុះ ៖ 17 Kg 4Kg និង 1Kg
- ទំហំគ្របដណ្តប់:
  - 9 $m^2$ / Kg លើដែក (លាប២ទឹក ជិតយ៉ាងល្អ)
  - 4 $m^2$ / Kg លើឈើ (លាប២ទឹក ជិតយ៉ាងល្អ)
- <u>គោលដៅប្រើប្រាស់:</u> សំណង់សង់ពីឈើ និងដែកគ្រប់ប្រភេទ។

**បញ្ជាក់:**

*ក្រៅពីថ្នាំលាបលាយប្រេង យើងមានថ្នាំទ្រនាប់សម្រាប់ឈើ និង ថ្នាំការពារច្រេះសម្រាប់លោហៈផងដែរ។*



## ៣៣ខ្មែរ

**ភាពភ្លឺសាយល្អ សាច់ពណ៌ល្អ ធន់ប្រើបានខ្ពស់**
**ទោះលាបម្តង ប្រើបានយូរឆ្នាំ សាងសប្បាយ**



- <u>ប្រភេទផលិតផល:</u> ថ្នាំប្រេង ភ្លឺរលោងល្អម
- <u>លក្ខណពិសេសនៃផលិតផល:</u> M33 ជាថ្នាំលាបប្រភេទលាយប្រេង ដែលងាយស្រួលលាប ឬបាញ់ លាបជាប់ជិត ប្រើចំណេញជាងគេ និងមានសាច់ភ្លឺល្អមស្អាត។
- <u>ចំណាត់ថ្នាក់ផលិតផល:</u> ថ្នាំលាបប្រភេទលាយប្រេង ដែលមានគុណភាពល្អ ។
- <u>ការប្រើប្រាស់:</u> ប្រើបានទាំងក្នុង និង ក្រៅ លាបលើដែក និង ឈើដើម្បីលំអ និងការពារ ។
- <u>ចំណុះ:</u> 18 Kg, 4Kg, 1Kg
- <u>ទំហំគ្របដណ្តប់:</u>
  - 6 $m^2$ / Kg លើដែក (លាប២ទឹក ជិតយ៉ាងល្អ)
  - 4 $m^2$ / Kg លើឈើ (លាប២ទឹក ជិតយ៉ាងល្អ)
- <u>ពណ៌:</u> មានច្រើនពណ៌សម្រាប់ជ្រើសរើស
- <u>គោលដៅប្រើប្រាស់:</u> សំណង់សង់ពីឈើ និងដែកគ្រប់ប្រភេទ។

# ថ្នាយអស្ទូត




- **កំផែងស និង វិមានស** ជាម្សៅបៀកពណ៌ស ដែល ស្រួលកូរ ស្រួលបៀក គោងស្អិតល្អ បៀកចំណោញ សាច់ហាប់រឹងស្អិត ឈ្នះទឹក និងជាប់បានយូរ ព្រោះវាត្រូវបានផលិតឡើងតាមរូបមន្តដែលលាយការច្រើន ។
- **កំផែងស និង វិមានស** *ជាជម្រើសល្អបំផុតសម្រាប់សំណង់ពណ៌ស* និងត្រូវការផលិតផលដែលល្អជាប់បានយូរ
- **ទម្ងន់:**
  - កំផែង ស 25Kg
  - វិមានស 20Kg
- **ថ្លៃគ្របដណ្តប់:**
  - កំផែង ស ប្រមាណ 14$m^2$ /បាវ
  - វិមានស ប្រមាណ 11$m^2$ /បាវ



## ឃីង ផ្លាស
## (KING PLAST)

- ជាម្សៅបៀក ពណ៌ទឹកប្រាក់/ប្រផេះ ដែលត្រូវបានផលិតឡើងតាមរូបមន្តដែលមានការច្រើន ពិសេសធ្វើឱ្យស្រួលកូរ ស្រួលបៀក គោងស្អិតល្អ បៀកចំណេញ សាច់ហាប់រឹងស្អិត ឈ្នះទឹក និងជាប់បានយូរ ។
- *ជាជម្រើសល្អបំផុតសម្រាប់សំណង់ពណ៌ប្រផេះឬពណ៌ចាស់ៗ* និងត្រូវការផលិតផលដែលល្អជាប់បានយូរ។
- ទម្ងន់: 25 Kg
- ផ្ទៃគ្របដណ្ដប់: ប្រមាណ 14m²/បាវ



## បាន ស៊ី
## BAN. ce

## ហូម ផ្លាស
## HOME PLAST

- បានស៊ី និង ហូមផ្លាស ជាម្សៅបៀកពណ៌ពងមាន់ ដែលផលិតឡើងតាមរូបមន្តពិសេស ងាយស្រួលប្រើ ជាប់ធន់បានល្អ និងចំណេញ ។
- បានស៊ី និង ហូមផ្លាស ជាជម្រើសល្អបំផុតសម្រាប់សំណង់ពណ៌ពងមាន់ រឺស្រទៀងពងមាន់ និងសំណង់ឧស្សាហកម្មទូទៅ ។
- ទម្ងន់:
  - បានស៊ី 20Kg
  - ហូមផ្លាស 33Kg

ផ្ទៃគ្របដណ្ដប់:

បានស៊ី ប្រមាណ 11m²/បាវ

ហូមផ្លាស ប្រមាណ 18m²/បាវ



# តែង ( TAENG )

បាយអលាយស្រាប់ ប្រើជាទ្រនាប់ ឬផ្ទៃ
សម្រេច ដើម្បីទទួលបានសាច់ពណ៌ស្មើ
ការពារស្នាមប្រេះ និងការបែកក្រឡាខ្លីង
ព្រមទាំងការពារអគារទាំងមូលផងដែរ។

# ណេវើដ្រប

# ( NEVERDROP )

ស៊ីម៉ង់ត៍ការ ដែលលាយស្រេចតាមរូបមន្ត
ស្តង់ដារ សម្រាប់បិទការ៉ូកាជន៍ដី ងាយ
ស្រួលប្រើ ជាប់ស្អិតល្អ (ផ្ទៃបញ្ឈរ និងផ្តេក)
សាច់បាយអណែន ព្រោះមានកាវច្រើន។




# មីសស្ទើហ្វិច

# (MR. FIX)

បាយអសម្រាប់ជួសជុល
តាមការទុយោ ទម្រជើង
ម៉ាស៊ីន ផ្ទិតសំបុកឃ្មុំ
លើផ្ទៃបេតុងបន្ទាប់ពីដោះ
ក្តារពុម្ព និងជួសជុល
ស្នាមប្រេះផ្សេងៗ ។ល។



# ប្រភេទគីមីសំណង់

## ណូម័រលីក

## (NO MORE LEAK)




ល្បាយ សម្រាប់ការពារជម្រាបទឹក

ជាភ្នាសការពារជម្រាបទឹកដែលមានភាពបត់បែនខ្ពស់។

ផ្នែកទី១ (A) គឺជាប្រភេទកាវ (Styrene Butadiene Rubber)

ផ្នែកទី២ (B) ជាបាយអស្ងួតម៉ដ្ឋល្អ

ដែលលាយជាមួយនឹងសារធាតុគីមីសំណង់សម្រាប់ធ្វើការងារការពារជម្រាបទឹក។ ផ្នែកទាំងពីរ (A) និង(B) បន្ទាប់ពីលាយបញ្ចូលគ្នាដោយត្រឹមត្រូវវានឹងក្លាយជាល្បាយធុកវមួយប្រភេទ ដែលមានកម្រិតតោងស្អិតខ្លាំង និងអាចការពារការជ្រាបទឹកបានយ៉ាងមានប្រសិទ្ធភាព និងយូរអង្វែងទៅលើផ្ទៃជាច្រើនប្រភេទ។

- **គុណសម្បត្តិ**

  - គ្មានសារធាតុពុល (អាចប្រើជាមួយកន្លែងផ្ទុកទឹកប្រើប្រាស់)
  - ងាយស្រួលប្រើប្រាស់
  - កម្លាំងតោងស្អិតខ្លាំង
  - កម្រិតធន់នឹងការជ្រាបទឹកខ្ពស់
  - មានភាពបត់បែនខ្ពស់ធន់នឹងការប្រេះ

- **ការវេចខ្ចប់**

  25 kg / ធុង (A:10 kg និង B:15 kg)

  4.5 kg x 4 / កេស (A:1.8 kg និង B:2.7 kg)

- **បរិមាណប្រើប្រាស់** 2-3 kg / $m^2$

- **គោលដៅប្រើប្រាស់**

  សម្រាប់ផ្ទៃផ្តេក និងបញ្ឈរ ផ្ទៃបាតបន្ទប់ទឹក ផ្ទៃអាងហែលទឹក និងដំបូលអគារ




# កាវឡាតិក្ស

## (CL-10)

សម្រាប់លាយក្នុងបាយអ ដើម្បីបង្កើនប្រសិទ្ធភាពរបស់បាយអ ឬ បេតុង ជម្រុញឲ្យកាន់តែប្រសើរឡើងនូវការតោងស្អិត ស្អិតជាប់ និងភាពបត់បែនខ្ពស់ ធ្វើឲ្យជាប់គង់វង្សបានយូរ។

**កាវឡាតិចការពារជ្រាបទឹក**

- **គុណសម្បត្តិ**

  - គ្មានសារធាតុពុល (អាចប្រើជាមួយកន្លែងផ្ទុកទឹកប្រើប្រាស់)
  - មានកម្រិតតោងស្អិតខ្ពស់ និងរួមផ្សំជាមួយសមាសធាតុបន្ថែមបានល្អ
  - បង្កើនភាពបត់បែន និងបន្ថយការប្រេះរបស់បេតុង
  - ជួយឲ្យបាយអ ឬបេតុងធន់នឹងទឹក
  - បង្កើនប្រសិទ្ធភាពបាយអ ឬបេតុង ធន់នឹងភាពសឹករេចរិល
  - ធន់នឹងសារធាតុគីមីផ្សេងៗ

- **ការវេចខ្ចប់**

  25 L (លីត្រ) / ធុង

  5 L (លីត្រ/ x4 / កេស)

- **ការប្រើប្រាស់**

  - លាយក្នុងបាយអ បង្កើនភាពស្អិត និងការពារការជ្រាបទឹក
  - ប្រើជាថ្នាំលាបស្តើង ការពារការជ្រាបទឹក (ផ្ទៃបាត: បន្ទប់ទឹក អាងទឹក ។ល។)
  - លាយក្នុងបេតុងក្រឡុក ដើម្បីបង្កើនប្រសិទ្ធភាពបេតុង

- **គោលដៅប្រើប្រាស់**

  សំណង់អគារគ្រប់ប្រភេទ




# ទឹកថ្នាំលាយបាយអរ

## (CCOMO)

**ទឹកថ្នាំលាយបេតុង រឺ បាយអ**
**ដើម្បីជួយឱ្យមានរលាក់ទឹក**

# ដៃគូរអាជីវកម្មរបស់យើង

**ចាំ -ថែង** គិតពីគុណភាពផលិតផលជាអាទិភាព ដូច្នេះគុណភាពវត្ថុធាតុដើមជាកត្តាចម្បងរបស់យើង ចំណែកថ្លៃជាកត្តាបន្ទាប់បន្សំ ហេតុដូច្នេះហើយបានជាយើងជ្រើសរើសយកក្រុមហ៊ុនដែលអាចធានាបាននូវគុណភាព ធ្វើជាដៃគូរផ្គត់ផ្គង់វត្ថុធាតុដើមអោយយើង។ ក្រុមហ៊ុនទាំងនោះរួមមានដូចជា៖

| | |
|---|---|
| BASF We create chemistry | DOW |
| DUPONT® | WACKER |
| DKSH | JEBSEN & JESSEN |
| nuplex | CLARIANT |
| CONNELL BROS. A DIVISION OF WILBUR-ELLIS | MahaChem market innovation |
| LORAMA GROUP | AgeD'orgroup |

# អតិថិជននិងសមិទ្ធិផលរបស់ក្រុមហ៊ុន








BOREY LIM CHHEANCHHAK



BOREY LAY KONG



NT





Borey Hi-tech



**BOREY MOHA SETHEY**





សំណង់របស់អតិថិជន នៅបន្ទាយមានជ័យដែលបានប្រើប្រាស់ទឹក
ពណ៌ស ថ្នាំទ្រនាប់ Max Extra E និងថ្នាំលាបក្រៅ សារ៉ែក។











# ទំនួលខុសត្រូវក្នុងសង្គមរបស់យើង

ក្រុមហ៊ុន ខេមបូឌាន ខេមីខល ស៊ីបផ្លាយ (ខ៉ាំ-ផែន) ក្រៅពីការធ្វើអាជីវកម្មដើម្បីប្រាក់ចំណេញ យើងក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពសង្គម។
សកម្មភាពដែលយើងបានកំពុងធ្វើរួមមានដូចជា៖

- រាល់សារធាតុគីមី ដែលអាចប៉ះពាល់ដល់សុខភាពមនុស្ស និង បរិស្ថាន គឺក្រុមហ៊ុនយើង មិននាំចូលមកប្រើប្រាស់ជាដាច់ខាត ទោះបីច្បាប់ក្នុងប្រទេសយើងមិនទាន់បានតឹតត្បិតដល់ក៏ដោយ។

- យើងប្តេជ្ញាជួលបុគ្គលិកជាជនជាតិខ្មែរ ១០០% ដើម្បីចូលរួមចំណែក ក្នុងការកសាង និង អភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេសរបស់យើង។

- យើងចូលរួមជួយជ្រោមជ្រែងរាល់សកម្មភាពដែលនាំអោយមានការរីកចម្រើនលើវិស័យ អប់រំ ទេសចរណ៍ និង សហគ្រាសខ្នាតតូចនិងមធ្យមនៅក្នុងប្រទេសកម្ពុជារបស់យើង តាមរយៈការជួយឧបត្ថម្ភដល់អង្គការ សមាគមន៍នានាដែលរៀបចំធ្វើកម្មវិធីទាំងអស់នោះ។

- ក្រៅពីនេះនាយកក្រុមហ៊ុនយើង ក៏តែងតែ ផ្តល់នូវការចែករំលែកពីបទពិសោធន៍គ្រប់គ្រងអាជីវកម្ម ភាពជាអ្នកដឹកនាំ និង ការធ្វើទីផ្សារ តាមរយៈកម្មវិធីសិក្ខាសាលា និង កម្មវិធីទូរទស្សន៍នានាជាប្រចាំ។




សកម្មភាពដែល នាយកក្រុមហ៊ុនទាំ-ផែន ចូលរួមចែករំលែកបទពិសោធន៍ក្នុងកម្មវិធីផ្សេងៗក្នុងសង្គម





សកម្មភាពដែល ក្រុមហ៊ុនទាំ-ផែន ចូលរួមជួយឧបត្ថម្ភ ក្នុងកម្មវិធីផ្សេងៗក្នុងសង្គម





សកម្មភាពដែល ក្រុមហ៊ុនទាំ-ផែន ចូលរួមបរិច្ចាគជាថវិកានិងសម្ភារៈជួយដល់អង្គការផ្សេងៗក្នុងសង្គម

# អាសយដ្ឋានក្រុមហ៊ុន



ផ្លូវលេខ២១៧ (ផ្លូវជើងឯក) ភូមិក្រាំងស្វាយ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ: +855 (0) 15 888 010 / 15 999 453 / 97 688 5657

គេហទំព័រ: www.campaint-ccsc.com.kh

អ៊ីម៉ែល: info@campaint-ccsc.com.kh



# បណ្តាញចែកចាយរបស់យើង




| ខេត្ត | ភ្នាក់ងារចែកចាយ | ទូរស័ព្ទ |
|---|---|---|
| • ភ្នំពេញ(តំបន់១) | ពណ្ណរាយ | 016 843 780 / 011 700 131 |
| • ភ្នំពេញ(តំបន់២) | ជោគជ័យ | 010 888 666 / 085 904 999 |
| • សៀមរាប | សោភ័ណអង្គរ | 092 123 678 / 016 775 589 |
| • កំពង់ចាម/ ត្បូងឃ្មុំ | ភ្នំប្រុសភ្នំស្រី | 016 778 168 / 012 944 007 |
| • ក្រចេះ | សីមាសោភា | 092 433 008 / 012 900 950 |
| • កំពង់ធំ/ព្រះវិហារ/ឧត្តរមានជ័យ | ជីវីជាន់ខ្លា | 015 888 001 / 017 373 839 |
| • កំពង់ស្ពឺ | វិចិត្រក្បាលមេឃ | 015 227 768 / 089 227 768 |
| • បាត់ដំបង/ប៉ៃលិន/ពោធិ៍សាត់ | គួយវណ្ណៈ | 012 940 771 / 098 277 268 |
| • ប៉ោយប៉ែត/បន្ទាយមានជ័យ | មុកខួច | 012 400 325 / 015 747 563 |
| • តាកែវ | ហុកឧត្តា | 015 98 69 69/ 089 22 00 66 |
| • កំពត/កែប | ហាឡុងអូន | 016 682 418 / 092 220 965 |
| • កំពង់សោម/កោះកុង | ហោតិមណោង | 016 71 0000 / 098 60 00 21 |
| • កំពង់ឆ្នាំង | វណ្ណៈសោភា | 098 955 053 / 017 441 766 |
| • មណ្ឌលគិរី | ហេងមនោរម្យ | 015 687 842 / 012 68 78 42 |
| • ព្រៃវែង/ស្វាយរៀង | ជាវិរៈ | 015 600 684 / 012 781 415 |
| • ស្ទឹងត្រែង/រតនគិរី | ជួបជា | 096 98 72 778/011 411 511 |


VITAL
KING
MAX EXTRA
CIP-11